# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៣០៩ អក-៩០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងការពារជាតិ**

**កម្មវត្ថុ:** អំពីការចោទប្រកាន់លើយោធិន ដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ ។

ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា តាំងពីមានព្រះរាជក្រមប្រកាសអោយប្រើច្បាប់ ស្តីពីលក្ខន្តិកៈរបស់យោធា នៅខេត្ត-ក្រុង មួយចំនួនដែលយោធិនបានប្រព្រឹត្តខុសច្បាប់ ព្រះរាជអាជ្ញាអមតុលាការនៅខេត្ត-ក្រុងនោះបានធ្វើការចោទដោយផ្ទាល់តែម្តងមិនបានសុំការអនុញ្ញាតពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងការពារជាតិទេ គ្រាន់តែបានជម្រាបជាលាយល័ក្ខអក្សរទៅមេបញ្ជាការដែលគ្រប់គ្រងយោធិននោះនៅតាមខេត្ត ។

ខ្ញុំសូមបញ្ជាក់ផងដែរជូនឯកឧត្តមម្តងទៀតថា មាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈនៃមន្ត្រីរាជការស៊ីវិល មិនគ្របដណ្តប់លើយោធិនទេ ។

អាស្រ័យហេតុនេះ ការដំណើរការរបស់អយ្យការ តុលាការខាងលើនេះប្រព្រឹត្តទៅត្រឹមត្រូវហើយ ។

ដើម្បីជៀសវាងបញ្ហាដែលអាចកើតឡើងជាយថាហេតុ ខ្ញុំសូមឯកឧត្តមមេត្តាពិនិត្យលទ្ធភាពសរសេរណែនាំទៅមេបញ្ជាការយោធភូមិភាគ ឬតំបន់ និងគ្រប់ខេត្តក្រុងផងអោយជួយសហការបញ្ជូនយោធិនដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ទៅតុលាការ ដើម្បីអយ្យការធ្វើការស៊ើបសួរ ក៏ឱ្យចូលខ្លួនតាមការអញ្ជើញរបស់តុលាការ ដើម្បីបំភ្លឺក្នុងរឿងរដ្ឋប្បវេណីដែលភាគីម្ខាងទៀតជាយោធិន ប្រជាជនស៊ីវិលបានប្តឹងទៅតុលាការ ។

ខ្ញុំយល់ថាការរួមចំណែករបស់ឯកឧត្តមក្នុងការសហការណ៍ជាមួយនិងក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ឱ្យច្បាប់ និងសិទ្ធិមនុស្សត្រូវបានគោរពក្នុងទូទាំងប្រទេសមានតម្លៃធំធេងណាស់ក្នុងការពង្រឹងដំណើររបស់កម្ពុជាយើងឱ្យទៅជានីតិរដ្ឋហើយជាពិសេសក្នុងកាលៈទេសៈចំពោះមុខនេះ ដែលយើងកំពុងរៀបចំការបោះឆ្នោតសម្រាប់ខែកក្កដា ១៩៩៨ ហើយដែលយើងទាំងអស់គ្នាចង់បានឱ្យមតិជាតិ និងអន្តរជាតិទទួលស្គាល់ថា ការបោះឆ្នោតរបស់យើងប្រព្រឹត្តទៅក្នុងសភាពរៀបរយនិងសន្តិសុខ ហើយដោយសេរី និងយុត្តិធម៌ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនឯកឧត្តមទុកជាមុន សូមឯកឧត្តមទទួលអំពីខ្ញុំនូវការគោរពរាប់អានខ្ពង់ខ្ពស់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ ព្រះរាជធិបតី នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម (ជូនសម្តេច ព្រះរាជតំណាងជ្រាប)។
-រដ្ឋសភា ( គណៈកម្មការការពារសិទ្ធមនុស្ស )
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី២
-ក្រសួងមហាផ្ទៃ
-តុលាការគ្រប់ជាន់ថ្នាក់
-តុលាការយោធិន
- កាលប្បវត្តិ ឯកសារ